សារព័ត៌មាន
សេរីភាពថ្មី
The New Liberty News
ថ្ងៃ ពុធ ទី 25 ខែ វិច្ឆិកា ឆ្នាំ 2009

# ស្ងាត់ៗទាហានយួនលបដកតម្រុយបង្គោលព្រំដែន ចូលដីខ្មែរចំនួនបីកន្លែងទៀតដើម្បីបំបាត់ភស្តុតាង

ដោយ : ពន្យ ពុទ្ធិ

បន្ទាប់ពីមេដឹកនាំគណបក្សប្រឆាំងធ្វើឱ្យបែកធ្លាយរឿងយួនមកបោះបង្គោលតម្រុយព្រំដែនលើដីស្រែកសិករខ្មែរនៅឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀងនោះមក បញ្ហាព្រំដែនខ្មែរភាគខាងកើតដែលត្រូវយួនរំលោភយកបានក្លាយទៅជារឿងធំ ដែលធ្វើឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរយួន-ខ្មែរ

មានការរសើប,ហើយក៏លេចចេញថាទាហាន យួនបានលើកគ្នាមកលបដកបង្គោលតម្រុយព្រំដែនដែលគេបានបោះត្រុយក្នុងគម្រោងចាក់គ្រឹះថ្មឱ្យទៅជាដីរបស់គេបើសិនជាគ្មានការប្រឆាំង តបតនោះ។ប៉ុន្តែឥឡូវបន្ទាប់ពីមានការសើរើតបតយ៉ាងប្តូរផ្តាច់ពីមេដឹកនាំគណបក្សប្រឆាំងទាហានយួនបាននាំគ្នាមកដកបង្គោលតម្រុយព្រំដែនបីកន្លែងទៀតទៅវិញហើយ ។ ដែលជាការបញ្ជាក់ឱ្យឃើញថា យួនតាមរយៈការធ្មេចភ្នែកពីសំណាក់អាជ្ញាធររដ្ឋាភិបាលខ្មែរពិតជាបានប៉ុនប៉ងខ្បៀលយកទឹកដីខ្មែរតាមរយៈវិធីបោះបង្គោលព្រំដែននេះដោយឥតអៀនខ្មាស់មែន។

ផ្អែកតាមប្រភពពីលោក*ពៅ ធាប* ជំទប់ទីពីរឃុំសំរោងជាឃុំដែលមានបញ្ហាយួនបោះបង្គោលព្រំដែនប្រុងខ្បៀលយកដីស្រែកសិករខ្មែរនោះថាបន្ទាប់ពីលោក*សម រង្ស៊ី* បានដកបង្គោលឈើដែលគេត្រុយប្រុងបោះបង្គោលឡាក់ព្រំដែនលេខ១៨៥កាលពីថ្ងៃទី២៥ខែកន្លងទៅហើយបានកើតមានជារឿងធំនោះឥឡូវទាហានយួនបានលើកគ្នាមកលួចដកតម្រុយព្រំដែនចំនួនពកន្លែងទៀតយកទៅហើយគឺបង្គោលឡាក់លេខ១៨៤,១៨៦,និង១៨៧ ។ដែលនេះត្រូវបានលោកយល់ថាគឺគេធ្វើឡើងដើម្បីបំបាត់ភស្តុតាងយកល្អមុខ ខណៈដែលលោក*សម រង្ស៊ី* បានរកឃើញពីពុតត្បុតរបស់ពួកគេក្នុងការប៉ុនប៉ងរំលោភយកដីខ្មែរតាមរបៀបឆៅៗនោះ។

ជំទប់ទីពីរនៃឃុំសំរោងរូបនេះបានបន្តឱ្យដឹងកាលពីព្រឹកថ្ងៃអង្គារម្សិលមិញថាបើចង់ដឹងការពិតថាយួនរំលោភដីខ្មែរ ឬមិនរំលោភនោះគេគួរតែបង្កើតគណៈកម្មាធិការចុះពិនិត្យមើលផ្ទាល់តែម្តងទៅ ថាតើធាតុពិតនោះវាយ៉ាងម៉េច ?

សក្ខីកម្មនិងភស្តុតាងនានាត្រូវបានគេរកឃើញជាបន្តបន្ទាប់ ខណៈដែលមេដឹកនាំគណបក្សប្រជាជនកំពុងតែព្យាយាមបិទបាំងការពិតនៃការធ្មេចភ្នែកបើកដៃឱ្យបរទេសបំពានយកដីខ្មែរតាមអំពើចិត្តនោះ។

មេដឹកនាំជាន់ខ្ពស់ទាំងបីនាក់នៃគណបក្សប្រជាជនកាន់អំណាចនៅកម្ពុជាទាំងនាយករដ្ឋមន្ត្រីទាំងប្រធានសភាជាតិទាំងប្រធានព្រឹទ្ធសភា ក្នុងលិខិតមួយចុះថ្ងៃទី១៦ខែវិច្ឆិកាឆ្លើយឆ្លើយតបអតីតព្រះមហាក្សត្រ ក្រោយពេលព្រះអង្គបានបញ្ជូនលិខិតរបាយការណ៍របស់លោក*សម រង្ស៊ី*ទៅប្រាប់អស់លោកទាំងនោះ អស់លោកទាំងបីនាក់បានចេញសេចក្តីថ្លែងការណ៍រួមមួយបដិសេធថាពុំមានប្រជារាស្ត្រខ្មែរណានៅខេត្តស្វាយរៀងបាត់បង់ដីស្រែដោយការបោះបង្គោលព្រំដែននោះទេ។

ជាប្រតិកម្មឆ្លើយតបវិញរបស់គណបក្សសមរង្ស៊ីដែល

លោក*សម រង្ស៊ី*សមាជិកសភាកម្ពុជាមួយរូបបានធ្វើជាសាក្សីផ្ទាល់ជាមួយប្រជារាស្ត្រម្ចាស់ដីស្រែនោះ គណបក្សប្រឆាំងក៏បានអធិប្បាយថា សេចក្តីថ្លែងការណ៍របស់មេដឹកនាំជាន់ខ្ពស់នៃគណបក្សកាន់អំណាចខុសពីស្ថានភាពជាក់ស្តែងនៃបញ្ហារបស់ប្រជារាស្ត្រផ្ទាល់។

ចំពោះការឆ្លើយបដិសេធរបស់មេដឹកនាំកំពូលទាំងបីនៃគណបក្សប្រជាជនទាំងនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ទាំងសភាជាតិ*ហេង សំរិន* ប្រធានព្រឹទ្ធសភា*ជា ស៊ីម* នៅក្នុងលិខិតរបស់លោកផ្ញើតបថ្វាយអតីតព្រះមហាក្សត្រខ្មែរនោះ លោក*យឹម សុវណ្ណ* សមាជិកសភាកម្ពុជាមួយរូបពីគណបក្សសមរង្ស៊ីនិងក៏ជាអ្នកនាំពាក្យរបស់គណបក្សបានមានយោបល់ថា អាចនឹងដឹងដោយសារការអនុញ្ញាតដល់ប្រជារាស្ត្រម្ចាស់ដីស្រែផ្ទាល់បានចូលគាល់ព្រះមហាក្សត្រកម្ពុជាឬអតីតព្រះមហាក្សត្រនោះ។

លោក*យឹម សុវណ្ណ* បានមានប្រសាសន៍យ៉ាងនេះថា "*បើចង់ដឹងរឿងពិតនោះឱ្យប្រជារាស្ត្រជាជនរងគ្រោះនៅកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀងបានចូលគាល់ព្រះករុណាអតីតព្រះមហាក្សត្រ ឬព្រះមហាក្សត្រដើម្បីទូលនូវរឿងពិត*"។

លោកបានបន្តបញ្ជាក់ទៀតថា អ្វីជាសេចក្តីថ្លែងការណ៍របស់មេដឹកនាំគណបក្សប្រជាជនទូលព្រះករុណាព្រះមហាក្សត្រអំពីស្ថានភាពដីស្រែរបស់ប្រជារាស្ត្រនៅឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀងនោះ គឺជាការមិនពិត។

លោកបានមានប្រសាសន៍យ៉ាងនេះថា "*សេចក្តីថ្លែងការណ៍នោះអត់ពិត។ ពិតតែនៅលើក្រដាស់ តែមិនពិតលើស្ថានភាពជាក់ស្តែង ដែលប្រជារាស្ត្រកំពុងរងគ្រោះដោយសារការបាត់បង់ដីធ្លីនៅក្នុងតំបន់នោះ*"។

មេដឹកនាំជាន់ខ្ពស់ផុតថ្នាក់ទាំងបីនៃគណបក្សប្រជាជន លោក*ជា ស៊ីម*ទាំងលោក*ហេង សំរិន* និងនាយករដ្ឋមន្ត្រី*ហ៊ុន សែន* នៅក្នុងសេចក្តីថ្លែងការណ៍រួមចុះថ្ងៃទី១៦ខែវិច្ឆិកាទូលថ្វាយព្រះករុណាព្រះបាទ*នរោត្តម សីហនុ* មេដឹកនាំនៃគណបក្សកំពុងកាន់អំណាចបានអះអាងថា មកដល់ពេលនេះពុំមានប្រជារាស្ត្រខ្មែរណាម្នាក់បាត់បង់ដីធ្លីរបស់ខ្លួនឡើយ។ មានការពន្យល់ភ្ជាប់ដោយហេតុផលថា ក្រុមបច្ចេកទេសព្រំដែនកំពុងបោះបង្គោល មិនទាន់បានធ្វើកិច្ចការខណ្ឌបង្គោលសីមាទេ ហើយភាគីទាំងពីរទាំងកម្ពុជានិងវៀតណាមមិនបានហាមឃាត់កសិករមិនឱ្យធ្វើស្រែនៅលើដីនោះដែរ។

នោះជាបញ្ហាដែលបានកើតឡើងក្លាយទៅជាលេចឮជាសាធារណៈក្នុងប្រទេស និងឆ្លងហួសព្រំដែនកម្ពុជាទៅឆាកអន្តរជាតិ ជាពិសេសនៅក្រោយពេលដែលប្រជាកសិករខ្មែរ" *បាននោឡោ*" ប្តឹងលោក*សម រង្ស៊ី* តំណាងរាស្ត្រកម្ពុជាមួយរូបរហូតដល់មានការដកបង្គោលតម្រុយ៦ដើមជាបង្គោលឈើពីដីកសិករខ្មែរ ១៦ខែក្រោយពីការប្តឹងរបស់ប្រជារាស្ត្រម្ចាស់ដីស្រែ សូមឱ្យរដ្ឋាភិបាលកម្ពុជានិងអាជ្ញាធរដោះស្រាយ ហើយពុំមានដំណោះស្រាយការពារដីប្រជាកសិករខ្មែរនោះ។

អំពីតម្រុយបង្គោលជុំវិញបង្គោលឡាក់លេខ១៨៥បោះដាំនៅលើដីស្រែរបស់កសិករខ្មែរភូមិកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀងនោះ មេដឹកនាំកំពូលទាំងបីនៃគណបក្សប្រជាជនកំពុងកាន់អំណាចបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍រួមរបស់អស់លោកថា ការបោះបង្គោលតម្រុយនោះអនុវត្តទៅតាមសិទ្ធិសញ្ញាឆ្នាំ១៩៨៥ចុះហត្ថលេខាសម័យកុម្មុយនិស្តដែលកងទ័ពវៀតណាមកំពុងកាន់កាប់កម្ពុជានិងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥។

មេដឹកនាំកំពូលទាំងបីនៃកម្ពុជាក៏បានអះអាងទៀតថា ការបោះបង្គោលតម្រុយនោះធ្វើដើម្បីនឹងកំណត់ខណ្ឌសីមាព្រំដែនដោយផ្អែកទៅតាមផែនទីមូលដ្ឋានដែលព្រះករុណាព្រះមហាវិរក្សត្របានយកទៅតម្កល់ទុកនៅអង្គការសហប្រជាជាតិក្នុងអំឡុងឆ្នាំ១៩៦៤។ អស់លោកបានរៀបរាប់ថា ការងារបោះបង្គោលតម្រុយនេះជាការពិបាក ដែលភាគីនីមួយៗមិនអនុញ្ញាតឱ្យភាគីមួយទៀតបានចំណេញដីដោយរំលោភលើបទដ្ឋានបច្ចេកទេសឡើយ។

ក៏មានការទូលថ្វាយថា

ភាគីទាំងពីរកម្ពុជានិងវៀតណាមនឹងអនុវត្តការបន្តបោះបង្គោលជាមួយការប្តេជ្ញាចិត្តនឹងបញ្ចប់ឱ្យស្រេចបាច់នៅមុនតំណាច់ឆ្នាំ២០១២។

ចៀសជាងទទួលស្គាល់នូវការពិតនៃហេតុការណ៍ដែលប្រជាកសិករខ្មែរម្ចាស់ដីស្រែរាប់ដំណរដូនតាខ្មែរធ្វើស្រែ ហើយដឹងយ៉ាងច្បាស់ថា ដីរបស់ពួកគាត់ដែលគណៈកម្មាធិការព្រំដែនទាំងពីរកម្ពុជា-វៀតណាមបានបោះបង្គោលលើ ដូច្នេះនឹងធ្វើឱ្យបាត់បង់ដីស្រែរបស់ពួកគាត់នោះ មេដឹកនាំទាំងបីនាក់នៃគណបក្សប្រជាជន បែរជាផ្តោតការចោទប្រកាន់ទៅលើលោក*សម រង្ស៊ី* លើបញ្ហាព្រំដែននេះទៅវិញ។

យោងតាមសេចក្តីថ្លែងការណ៍នោះ មេដឹកនាំគណបក្សកាន់អំណាចចោទប្រកាន់លោក*សម រង្ស៊ី*សមាជិកសភាកម្ពុជានិងជាប្រធាននៃគណបក្សប្រឆាំងដ៏ធំនៅកម្ពុជានោះថា លើកយកបញ្ហាព្រំដែនឡើងមកមកគ្រាន់តែដើម្បីទាក់ទាញសាធារណជនរកប្រជាប្រិយភាពរបស់ខ្លួននិងរបស់គណបក្សហើយរំខានដល់ការងាររដ្ឋាភិបាលដែលកំពុងដោះស្រាយបញ្ហាលំបាកនៃការឈ្លានពានរបស់ប្រទេសសៀមនៅព្រំដែនខាងលិច។

លោក*សម រង្ស៊ី* ដែលបានទៅជាសាក្សីផ្ទាល់និងបានឃើញការបោះតម្រុយហើយបានស្តាប់ឮនូវការអះអាងរបស់ប្រជារាស្ត្រម្ចាស់ដីស្រែថា ការបោះបង្គោលនោះគេបានធ្វើឡើងដោយឆ្លងប្រឡាយយុទ្ធសាស្ត្រពីខាងទឹកដីយួនមកខាងលិច និងបោះដាំបង្គោលតម្រុយនៅលើដីស្រែខ្មែរដែលមានបង្គោលឡាក់ចំនួន៣គឺលោក១៨៤ . ១៨៥ និង១៨៦ ចំណុចខ្លះឃើញចូលមកក្នុងដីខ្មែរដល់ទៅ៣២០ម៉ែត្រ។

លោក*យឹម សុវណ្ណ* អ្នកនាំពាក្យនៃគណបក្សសមរង្ស៊ីបានបញ្ជាក់ថា អ្វីដែលលោកប្រធាន*សម រង្ស៊ី* បានទូលរាយការណ៍ថ្វាយអតីតព្រះមហាក្សត្រខ្មែរដែលជាសាក្សីរស់ នៃខ្សែបន្ទាត់ព្រំដែនអំពីភាពរងគ្រោះរបស់ប្រជារាស្ត្រកសិករខ្មែរនោះ វាគឺជាការបំពេញករណីកិច្ចតំណាងរាស្ត្រដើម្បីជួយដោះស្រាយដល់ប្រជារាស្ត្រខ្មែរដែលបានបាត់បង់ដីស្រែនៅម្តុំបង្គោលឡាក់លេខ១៨៥។

បញ្ហាទឹកដីនៅតំបន់ជាយដែនដែលក្លាយទៅជារឿងនៃកង្វល់បារម្ភរបស់ប្រជារាស្ត្រខ្មែរម្ចាស់ដីស្រែនៅតំបន់នោះ ចាប់តាំងពីមានការបោះង្គោលព្រំដែនធ្វើឡើងដោយគណៈកម្មាធិការនៃប្រទេសទាំងពីរកម្ពុជា-វៀតណាម ផ្តើមក្នុងឆ្នាំ២០០៦ នៅក្រោយការធ្វើសន្ធិសញ្ញាបំពេញបន្ថែមខែតុលាឆ្នាំ២០០៥ នោះ មានការអធិប្បាយឆ្លើយចោទប្រកាន់គ្នាទៅវិញទៅមក។ ខាងគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជាដែលមានលោក*វ៉ា គឹមហុង*ជាប្រធានមជ្ឈដ្ឋាននេះបានអះអាងថាគ្មានដីស្រែរបស់ប្រជាកសិករខ្មែរណាបាត់បង់ដោយសារការបោះបង្គោលតម្រុយនិងបង្គោលឡាក់តាមខ្សែព្រំដែនដើម្បីធ្វើជាខណ្ឌសីមាកំណត់ព្រំប្រទល់នៃប្រទេសទាំងពីរនោះទេ។

ប៉ុន្តែ ប្រជាកសិករខ្មែរនៅទីនោះទាំងសមាជិកសភាគណបក្សប្រឆាំងដ៏ធំសមរង្ស៊ីនិងគណបក្សប្រឆាំងនានា រហូតដល់សកម្មជនព្រំដែនកម្ពុជាជាអ្នកជំនាញកិច្ចការផែនទីនិងស្គាល់ភូមិសាស្ត្របន្ទាត់ព្រំដែនខ្មែរយ៉ាងច្បាស់ ដូចជាគណៈកម្មាធិការព្រំដែននៃលោក*ស៊ាន ប៉េងសែ* នៅក្រុងប៉ារីសនោះ មជ្ឈដ្ឋានទាំងនេះបានអះអាងអំពីការបាត់បង់ដីខ្មែរទៅក្នុងការទន្ទ្រានយករបស់ប្រទេសជិតខាង ជាពិសេសប្រទេសយួន។

លោក*សម រង្ស៊ី*បានធ្វើការអះអាងចោទប្រកាន់ពីសហភាពអឺរ៉ុបជាទីដែលលោកកំពុងបំពេញការងាររកអន្តរាគមន៍ពីម្ចាស់ជំនួយអន្តរជាតិសម្រាប់ហេតុការណ៍ដែលកំពុងកើតមាននៅកម្ពុជា ទាំងការដកព្យួរអភ័យឯកសិទ្ធិសភារបសលោកនោះ ដោយនូវការថ្លែងរបស់លោកថា ដីខ្មែរនៅតំបន់ជាយដែនខាងកើតជាមួយយួនបាត់បង់អស់ទំហំរាប់ពាន់គីឡូម៉ែត្រការ៉េ ដោយសារតែសន្ធិសញ្ញាកម្ពុជា-វៀតណាម ក្នុងអំឡុងទសវត្សទី៨០។

វាគឺការនិយាយសំដៅដល់សន្ធិសញ្ញាចុះហត្ថលេខារវាងលោក*ហ៊ុន សែន* កាលនៅជារដ្ឋមន្ត្រីក្រសួងការបទេសជាមួយសមភាគីយួន*ង្វៀង កូថាច់*ក្នុងអំឡុងឆ្នាំ១៩៨២,១៩៨៣ នឹង

១៩៨៥ ហើយគឺសន្ធិសញ្ញាខែធ្នូឆ្នាំ១៩៨៥និយាយអំពីការកំណត់បោះបង្គោលព្រំដែន ដែលក៏ដោយសាររឿងនេះមានការធ្វើសន្ធិសញ្ញាបំពេញបន្ថែមក្នុងឆ្នាំ២០០៥ដែលរងការរិះគន់ពីសកម្មជនព្រំដែនក៏ដូចជាមជ្ឈដ្ឋានគណបក្សប្រឆាំងថាធ្វើឱ្យបាត់បង់ដីទៅក្នុងការកាន់កាប់របស់យួន។

លោក*សម រង្ស៊ី* ត្រូវបានសមាជិកសភាគណបក្សប្រជាជនប្រជុំផាត់សម្ងាត់បិទទ្វារកាលពីព្រឹកថ្ងៃទី១៦ខែវិច្ឆិកា ដកហូតព្យួរអភ័យឯកសិទ្ធិសភារបស់លោកនៅក្រោយបណ្ដឹងពីអាជ្ញាធរស្រុកចន្ទ្រាខេត្តស្វាយរៀងទៅតុលាការ ហើយក៏មានសំណើសុំពីតុលាការទៅក្រសួងយុត្តិធម៌នៃរដ្ឋាភិបាល ជាពិសេសធ្វើឡើងនៅក្រោយពេលដែលនាយករដ្ឋមន្ត្រីយួន*ង្វៀង តាន់ឌុង* បានមានប្រតិកម្មខឹងសម្បារ ហើយទាមទារឱ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការប្រឆាំងនឹងលោក*សម រង្ស៊ី* រឿងបង្គោលព្រំដែនដែលប្រជារាស្ត្រខ្មែរតវ៉ាដោយមានការជួយឈឺឆ្អាលរបស់សមាជិកសភាគណបក្សប្រឆាំងទាំងលោក*សម រង្ស៊ី* ផងនោះ។

ហើយដើម្បីជាការត្រូវសម្ដែងសេចក្ដីស្មោះត្រង់ចំពោះប្រជារាស្ត្រម្ចាស់ប្រទេសនោះ រដ្ឋាភិបាលកាន់អំណាចនិងអាជ្ញាធរកិច្ចការព្រំដែនរបស់ប្រទេសកម្ពុជាគួរណាស់តែហ៊ានបំពេញកិច្ចការដោយតម្លាភាពនិងបើកចំហឱ្យមានការចូលរួមពិនិត្យរបស់អ្នកជំនាញឯករាជ្យខាងព្រំដែនផែនទី អង្គការសង្គមស៊ីវិលជាពិសេសគណបក្សប្រឆាំងដើម្បីឱ្យដឹងថា ពិតជាពុំមានការបាត់បង់ដីស្រែរបស់ប្រជារាស្ត្រខ្មែរមែន ប្រសិនបើរដ្ឋាភិបាលមិនមានអ្វីត្រូវលាក់បាំង ហើយច្បាស់ប្រាកដថា ដីប្រជាកសិករខ្មែរមិនបាត់មែននោះ។ ឯប្រជារាស្ត្រម្ចាស់ដីស្រែគប្បីបានចូលគាល់ព្រះមហាក្សត្រនិងអតីតព្រះមហាក្សត្រដើម្បីទូលថ្វាយនូវរឿងពិតនៃអ្វីដែលពួកគាត់បានជួបប្រទះលើបញ្ហាដីស្រែតាមតំបន់ជាយដែននោះ។/